**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៤ ......សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩

# សេចក្តីជូនដំណឹង

ដើម្បីបន្តកែទម្រង់ក្នុងសង្គម ពង្រឹងសណ្តាប់ធ្នាប់សាធារណៈ និងកែលំអសីលធម៌សង្គម រាជរដ្ឋាភិបាល បានសម្រេច ៖

១- បិទអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) នៅទូទាំងប្រទេស ។ អាជ្ញាប័ណ្ណអាជីវកម្មទាំងឡាយណា ដែលបានផ្តល់ជូនកន្លងមកមិនទាន់ផុតសុពលភាព ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ ។

២- បិទអាជីវកម្មភ្នាល់កីឡាបាល់ទាត់នៅទូទាំងប្រទេស ។ អាជ្ញាប័ណ្ណអាជីវកម្មទាំងឡាយណា ដែលបានផ្តល់ជូនកន្លងមកមិនទាន់ផុតសុពលភាព ត្រូវចាត់ទុកជានិរាករណ៍ចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ ។

បានទទួលសេចក្តីជូនដំណឹងនេះហើយ អ្នកដែលមានអាជ្ញាប័ណ្ណសំរាប់អាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និង មេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) និង ល្បែងភ្នាល់កីឡាគ្រប់ប្រភេទនៅទូទាំងប្រទេស ត្រូវបញ្ឈប់សកម្មភាពជាបន្ទាន់ ។ ក្នុងករណីនៅតែចចេសរឹងរូស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ទន្ទឹមនឹងនេះ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ នឹងចាត់វិធានការបង្ក្រាប លុបបំបាត់រាល់ល្បែងស៊ីសងល្បួចលាក់ខុសច្បាប់គ្រប់ប្រភេទ តាមសមត្ថកិច្ច ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន:

- គ្រប់វិទ្យុ ទូរទស្សន៍ និងបណ្តាញសារព័ត៌មាន
- គ្រប់កាសែត និងទីភ្នាក់ងារសារព័ត៌មាន